# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា** ********

**លេខ ២៩ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ

*********

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

- បានឃើញព្រះរាជក្រមលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញព្រះរាជក្រមលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-បានឃើញអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០២ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវគោលការណ៍នៃការអនុវត្តឱ្យមានភាពស៊ីសង្វាក់គ្នា និងសង្គតិភាពនៃ ការអនុវត្តប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ សម្រាប់មន្ត្រីរាជការស៊ីវិល ដែលបំពេញ ការងារទៅតាមគម្រោងផ្សេងៗរបស់ក្រសួង ស្ថាប័ន ដែលធ្វើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍនានា តាមកិច្ចព្រមព្រៀងរវាងដៃគូអភិវាឌ្ឍជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា ២.-**

ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ គឺជាប្រាក់ឧបត្ថម្ភ បន្ថែមទៅលើប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់ បន្ទាប់បន្សំដទៃទៀត ជូនមន្ត្រីរាជការស៊ីវិលទាំងឡាយណា ដែលចូលរួមក្នុងការគ្រប់គ្រងការអនុវត្ត និងការផ្តល់ជំនាញឯកទេស ដល់ការអនុវត្តមុខសញ្ញាអភិវឌ្ឍជាយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ននានា តាមកិច្ចព្រមព្រៀងរវាងដៃគូអភិវឌ្ឍ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

ការអភិវឌ្ឍយុទ្ធសាស្ត្រជាទិភាព រួមបញ្ចូលកម្មវិធីអភិក្រមទូទាំងវិស័យ អាចផ្តល់មូលនិធិដោយដៃគូ អភិវឌ្ឍមួយ ឬច្រើន និងអាចប្រើប្រាស់គណនីដោយឡែក ដែលប្រមូលផ្តុំហិរញ្ញវត្ថុ ឬថវិកាគាំទ្រតាមវិស័យ។

## ជំពូកទី ២

## គោលការណ៍សំខាន់ៗ

**មាត្រា ៣.-**

ការអនុវត្តកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវគោរពតាមគោលការណ៍ សំខាន់ៗដូចខាងក្រោម៖

-ប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ជាឧបករណ៍សម្រាប់អនុវត្តមុខសញ្ញាជាយុទ្ធសាស្ត្រ ដែលអនុវត្តដោយមន្ត្រីមានសមត្ថភាពខ្ពស់បំផុត និងមានចំនួនតិច។

- ការអនុវត្តកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវតែមានសង្គតិភាពនៅក្នុង ប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធបៀវត្សរបស់រដ្ឋ។

- ប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ មិនអាចក្លាយជាគោលនយោបាយបៀវត្សទៅ ថ្ងៃអនាគតទេ។

- លក្ខខណ្ឌរបស់ដៃគូអភិវឌ្ឍ មិនត្រូវប៉ះពាល់ដល់ ឯកភាព ស្ថិរភាព និងនិរន្តរភាពនៃប្រព័ន្ធដែលមាន ស្រាប់នោះទេ។

**មាត្រា ៤**.~

គ្រប់មុខតំណែងទាំងអស់ ដែលត្រូវទទួលបានការឧបត្ថម្ភប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផល ការងារត្រូវសមស្រប ទៅនឹងមុខងារជាអាទិភាពរបស់ក្រសួង ស្ថាប័នសាមី។

មុខតំណែងនីមួយៗ ដែលទទួលបានប្រាក់លាភការបន្ថែមដោយ ផ្អែកលើលទ្ធផលការងារ ត្រូវមានការរៀបរាប់អំពីលក្ខខណ្ឌការងារជាលាយលក្ខណ៍អក្សរ មាននីតិវិធីជ្រើសរើស ផ្លាស់ប្តូរ ផ្អែកលើលទ្ធផលការងារ តម្លាភាពនិងសមត្ថភាព។

**មាត្រា ៥**.~

មន្ត្រីម្នាក់ៗ ដែលទទួលការជ្រើសរើសឱ្យបម្រើការងារ នៅក្នុងគម្រោងកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារត្រូវ៖

-មានកិច្ចសន្យាការងារ ស្តីពី គោលដៅ សកម្មភាពការងារ លទ្ធផលការងារជាបរិមាណ និងគុណភាព យន្តការតាមដានត្រួត ពិនិត្យ និងវាយតម្លៃ

-ទទួលការវាយតម្លៃយ៉ាងហោចណាស់មួយឆ្នាំម្តង តាមនីតិវិធី ដូចមានចែងក្នុងកិច្ចសន្យា

-ទទួលបាននូវការអភិវឌ្ឍសមត្ថភាព។

## ជំពូកទី ៣

## កម្រិតប្រាក់ឧបត្ថម្ភ និងការគាំទ្រ

**មាត្រា ៦**.~

មន្ត្រីរាជការស៊ីវិល ដែលត្រូវបានជ្រើសរើសឱ្យបំពេញការងារ ក្នុងគម្រោងផ្សេងៗ របស់ក្រសួង ស្ថាប័ន ដែលធ្វើហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ ត្រូវបានទទួលប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផល ការងារ ដូចខាងក្រោម៖

| | |
|---|---|
| -ថ្នាក់អគ្គនាយក ត្រូវទទួលបានចំនួន | ១.៨០០.០០០ រៀល |
| -ថ្នាក់អគ្គនាយករង ត្រូវទទួលបានចំនួន | ១.៤៨០.០០០ រៀល |
| -ថ្នាក់ប្រធាននាយកដ្ឋាន ត្រូវទទួលបានចំនួន | ១.២៨០.០០០ រៀល |
| -ថ្នាក់អនុប្រធាននាយកដ្ឋាន ត្រូវទទួលបានចំនួន | ១.០៨០.០០០ រៀល |
| -ថ្នាក់មន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវទទួលបានចំនួន | ១.០០០.០០០ រៀល |

-ថ្នាក់ប្រធានការិយាល័យ ត្រូវទទួលបានចំនួន ៩៣២.០០០ រៀល

-ថ្នាក់អនុប្រធានការិយាល័យ ត្រូវទទួលបានចំនួន ៨៣៦.០០០ រៀល

-ថ្នាក់មន្ត្រីក្រមការ ត្រូវទទួលបានចំនួន ៧៧២.០០០ រៀល

-ថ្នាក់លេខាធិការ ត្រូវទទួលបានចំនួន ៤៥២.០០០ រៀល

ប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ចាប់ពីថ្នាក់ក្រោមអនុប្រធាននាយកដ្ឋាន ត្រូវបានគិតបញ្ចូលប្រាក់កន្ស្រៀម អាទិភាព ដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ រួចជាស្រេច។

ប្រាក់លាភការបន្ថែម ផ្អែកលើលទ្ធផលការងារទាំងអស់ ត្រូវមានការពិនិត្យឡើងវិញជាប្រចាំ (ប្រចាំឆ្នាំ) និងធ្វើការផ្លាស់ប្តូរប្រសិនបើចាំបាច់។

ការផ្លាស់ប្តូរកម្រិតប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវធ្វើឡើងដោយអនុក្រឹត្យ។

**មាត្រា ៧**.-

មន្ត្រីរាជការស៊ីវិល ដែលមានមុខជំនាញបច្ចេកទេសពិសេស នឹងត្រូវទទួលប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ដែលមុខសញ្ញា និងកម្រិតប្រាក់ឧបត្ថម្ភ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

មុខតំណែងផ្សេងៗទៀត ដែលត្រូវទទួលប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ដែលពុំ មានចែងក្នុងមាត្រា ៦ ត្រូវកំណត់ថ្នាក់ស្មើនឹងមុខតំណែងក្នុងមាត្រា ៦ និងមានចែងក្នុងអនុស្សារណៈនៃការយោគយល់គ្នា។

**មាត្រា ៨**.-

មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបានកម្រិតប្រាក់លាភការបន្ថែមដូចគ្នា សម្រាប់តួនាទីដូចគ្នា។

**មាត្រា ៩**.-

ប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវផ្ទេរចូលទៅក្នុងគណនីផ្ទាល់ខ្លួន របស់មន្ត្រីរាជ ការម្នាក់ៗ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

**មាត្រា ១០**.-

ក្រសួង ស្ថាប័ននីមួយៗ ដែលបានផ្តួចផ្តើមកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវធានាចំពោះដៃគូអភិវឌ្ឍ ក្នុងការផ្ទេរហិរញ្ញប្បទានកំពុងដំណើរការ លើប្រាក់ឧបត្ថម្ភបន្ថែម ដើម្បីគាំទ្រដល់ ការអនុវត្តកម្មវិធីប្រាក់លាភការបន្ថែម ដោយ ផ្អែកលើលទ្ធផលការងារ។

**មាត្រា ១១**.-

អនុស្សារណៈនៃការយោគយល់គ្នាស្តីពីការគាំទ្រកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងាររវាងក្រសួង ស្ថាប័ន នានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ត្រូវរួមបញ្ចូលនូវ ថវិកាដំបូងរបស់ដៃគូអភិវឌ្ឍ ដែលមានចំនួនមិនលើសពីកៅសិបភាគរយ (៩០%) ក្នុងឆ្នាំទី១ ហើយចំនួននេះត្រូវ ថយចុះ ជាបន្តបន្ទាប់ចំនួនប្រាំភាគរយ(៥%) សម្រាប់អាយុកាលកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធ ផលការងារនីមួយៗ។

រាជរដ្ឋាភិបាលផ្តល់សហហិរញ្ញប្បទាន ដល់កម្មវិធីប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ក្នុងក្របខ័ណ្ឌថវិការបរិភាគិបស់រាជរដ្ឋាភិបាល។

**មាត្រា ១២**.~

កម្មវិធីប្រាក់លាភការបន្ថែម ប្រាក់លើសម៉ោង ឬការរៀបចំតាមកិច្ចសន្យាថ្មីសម្រាប់មន្ត្រីរាជការ ដែលជាផ្នែកមួយរបស់កម្មវិធី ឬគំរោងរបស់ដៃគូអភិវឌ្ឍ មិនត្រូវអនុញ្ញាតឱ្យមាននៅ ខាងក្រៅ កម្មវិធីប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារទេ។

**ជំពូកទី ៤**

**នីតិវិធីនៃការអនុម័ត**

**មាត្រា ១៣**.~

នីតិវិធីសម្រាប់អនុម័ត កម្មវិធីប្រាក់លាភការមន្ថែម ដោយផ្អែកលើលទ្ធផលការងារ ក្រសួង ស្ថាប័នត្រូវចាប់ផ្តើមដាក់សំណើទៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានអគ្គលេខាដ្ឋាន ក្រុមប្រឹក្សាកំណែទំរង់រដ្ឋាបាលជាសេនាធិការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សំណើត្រូវបង្ហាញដោយសង្ខេបពីទំនាក់ទំនងរវាង គោលបំណងនៃកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារដែលបានស្នើឡើង ជាមួយអាទិភាពជាយុទសាស្ត្ររបស់ក្រសួង ស្ថាប័ន គោលបំណង និងកម្មវិធីគាំទ្ររបស់ដៃគូអភិវឌ្ឍ ដោយផ្តល់តួលេខបញ្ជាក់ចំនួនមុខតំណែង និងចំណាយ ហើយត្រូវសង្ខេបនីតិវិធី សម្រាប់ធ្វើការត្រួតពិនិត្យ និងវាយតម្លៃ។

**មាត្រា ១៤**.~

ក្រោយពីបានទទួលការឯកភាពជាគោលការណ៍ នូវសំណើដែលមានចែងក្នុងមាត្រា ១៣ ខាងលើ ទម្រង់អនុស្សារណៈនៃយោគយល់គ្នាមួយ នឹងត្រូវបង្កើតឡើងដោយភាគីពាក់ព័ន្ធ ដោយមានភ្ជាប់នូវឯកសារណែនាំសំរាប់ការអនុវត្តកម្មវិធី ដែលបានអនុម័តដោយក្រសួង ស្ថាប័នសាមី។

ការមិនអនុវត្តតាមគោលការណ៍ និងនីតិវិធី ដែលបានចែងក្នុងឯកសារណែនាំជាទូទៅ ចាំបាច់ត្រូវបង្ហាញហេតុផលអោយបានច្បាស់លាស់។

ឯកសារណែនាំលំអិតត្រូវរៀបចំដោយក្រសួង ស្ថាប័ននីមួយៗ ដែលអនុវត្តកម្មវិធីប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារដោយបញ្ជាក់លំអិតនូវនីតិវិធីនានា សម្រាប់អនុវត្ត។

## ជំពូកទី ៥

## លក្ខខណ្ឌនៃការអនុវត្ត

**មាត្រា ១៥**.-

ចំនួនមុខតំណែង ដែលមានក្នុងកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវតំណាត់សម្រាប់មុខតំណែងសំខាន់ៗ ក្នុងការសម្រេចបាននូវយុទ្ធសាស្ត្រជាអាទិភាព របស់ក្រសួង ស្ថាប័ននីមួយៗ។

**មាត្រា ១៦**.-

ក្រសួង ស្ថាប័ន ដែលទទួលបានការយល់ព្រមលើកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវមានការទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី ស្របតាមអនុស្សរណៈនៃការយោគយល់គ្នា និងឯកសារណែនាំដែលបានអនុម័ត។

ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ជាសេនាធិការត្រូវមាន ភារកិច្ចទទួលខុសត្រូវ ក្នុងការអនុម័តនូវកម្មវិធី និងសម្របសម្រួល តាមដាន ត្រួតពិនិត្យ នៃការអនុវត្តកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ។

គ្រប់ក្រសួង ស្ថាប័ន ដែលអនុវត្តកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវធ្វើរបាយការណ៍បច្ចេកទេស ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលជាសេនាធិការ និងរបាយការណ៍ចំណាយជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៧**.-

ការផ្លាស់ប្តូរមន្ត្រី ដែលបានទទួលប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវធ្វើឡើងដោយតម្លាភាព និងរក្សាចំនួនមន្ត្រីឱ្យនៅដដែល តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី និងចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១៨**.-

ការប្រើប្រាស់កម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ត្រូវបញ្ចប់នៅពេលដែលការធ្វើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ ត្រូវបានបញ្ចប់ ឬគម្រោងត្រូវបានបញ្ចប់។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

**មាត្រា ១៩**.-

គ្រប់កម្មវិធីប្រាក់លាភការបន្ថែមរបស់ដៃគូអភិវឌ្ឍ ដែលមិនស្របជាមួយបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវបញ្ឈប់ ឬបង្វែរថវិការចូលទៅក្នុងកម្មវិធីប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ដែលរៀបចំឡើងតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក្នុងរយៈពេលមិនពីមួយឆ្នាំក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ២០**.-

អនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តលាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ និងអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ស្ដីពីការកែសម្រួល ការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូនសម្ដេច នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

**សុខ អាន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គស្នងការដ្ឋានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចមាត្រា ២១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

- តារាង ប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ កន្សោមអទិភាព និង MBPI (Merit Based Performance Incentives)

| | បៀវត្សមូលដ្ឋាន | | ប្រាក់បំណាច់មុខងារ | | កន្សោមអាទិភាព | | សរុបជារៀល | | សរុបជាដុល្លារ | | ប្រាក់បន្ថែមពីគំរោងផ្សេងៗ | សរុបទូទៅ | | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | អប្បបរិមា | អតិបរមា | អប្បបរិមា | អតិបរមា | រៀល | ដុល្លារ | អប្បបរិមា | អតិបរមា | អប្បបរិមា | អតិបរមា | | អប្បបរិមា | អតិបរមា | |
| | 1 | 2 | 3 | 4 | 5 | | 6 | 7 | 8 | 9 | 10 | 8 | 9 | |
| អគ្គនាយក | 261,600 | 330,000 | 735,000 | 929,000 | 0 | | 996,600 | 1,259,000 | 249 $ | 314 $ | 450 $ | 699 $ | 764 $ | |
| អគ្គនាយករង | 261,600 | 292,200 | 645,000 | 815,000 | 0 | | 861,600 | 1,107,200 | 215 $ | 276 $ | 370 $ | 585 $ | 646 $ | |
| ប្រធាននាយកដ្ឋាន | 261,600 | 292,200 | 620,000 | 786,000 | 0 | | 836,600 | 1,078,200 | 209 $ | 269 $ | 320 $ | 529 $ | 589 $ | |
| អនុប្រធាននាយកដ្ឋាន | 189,000 | 255,000 | 540,000 | 706,000 | 0 | | 729,000 | 961,000 | 182 $ | 240 $ | 270 $ | 452 $ | 510 $ | |
| មន្ត្រីគ្រប់គ្រងរដ្ឋបាល | 189,000 | 255,000 | 65,000 | 113,700 | 520,000 | 130$ | 774,000 | 888,700 | 193 $ | 222 $ | 120 $ | 313 $ | 342 $ | 250$ |
| ប្រធានការិយាល័យ | 189,000 | 231,000 | 78,100 | 136,600 | 450,000 | 113$ | 712,900 | 817,600 | 178 $ | 204 $ | 120 $ | 298 $ | 324 $ | 233$ |
| អនុប្រធានការិយាល័យ | 151,200 | 204,000 | 61,400 | 107,400 | 450,000 | 113$ | 662,600 | 761,400 | 165 $ | 190 $ | 96 $ | 261 $ | 286 $ | 209$ |
| មន្ត្រីក្រមការ | 132,000 | 178,200 | 35,500 | 64,000 | 450,000 | 113$ | 618,500 | 692,200 | 154 $ | 173 $ | 80 $ | 234 $ | 253 $ | 193$ |
| នាយលេខាធិការ | 127,200 | 157,200 | 24,000 | 42,100 | 250,000 | 63$ | 401,200 | 449,300 | 100 $ | 112 $ | 50 $ | 150 $ | 162 $ | 113$ |
| លេខាធិការដើមខ្សែរ | 103,800 | 139,800 | 24,000 | 42,100 | 250,000 | 63$ | 377,800 | 431,900 | 94 $ | 107 $ | 50 $ | 144 $ | 157 $ | 113$ |
| លេខាធិការ | 90,000 | 121,200 | 24,000 | 42,100 | 250,000 | 63$ | 364,000 | 413,300 | 91 $ | 103 $ | 50 $ | 141 $ | 153 $ | 113$ |

- (6) = (1) + (3) + (5)
- (7) = (2) + (4) + (5)
- (8) = (6) គិតជាដុល្លា ( ១ដុល្លា = ៤000 រៀល )
- (9) = (7) គិតជាដុល្លា ( ១ដុល្លា = ៤000 រៀល )
- (10) & (13) = ជាប្រាក់ MBPI តាមរយះគំរោងនានាដែលមានហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
- (11) = (8) + (10)
- (12) = (9) + (10)
- (13) = ប្រាក់ MBPI នៅក្រោមថ្នាក់ អនុប្រធាននាយកដ្ឋាន បែងចែកជា ២ : មួយផ្នែក សំរាប់ កន្សោមអាទិភាព នៅក្នុង colonne ទី ៥ និង មួយផ្នែកទៀត ជាប្រាក់បង្គ្រប់នៅក្នុង colonne ទី ១០